# មេរៀនទី ១០៨៖ អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ

## ម៉ាថាយ ២៖១-១២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/WtTeDh0HJUo

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/JOmzOFJDmiM

**Worship Theme: Everyone needs Jesus.**
**គោលបំណង៖ មនុស្សគ្រប់គ្នាត្រូវការព្រះយេស៊ូវ។**

**ខគម្ពីរចងចាំ៖ ម៉ាថាយ ១០៖១៣** *"ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ។ "*

**ចំរៀង** ( *យូធូបលីង* )៖
១. ហោរាពីទិសខាងកើត https://youtu.be/UFeP7HQQHMo
២. ចូរសរសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM
៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «កងចក្រណាចា»

សម្ភារៈដែលត្រូវការ៖ គ្រាប់ប៉េងប៉ុង (ឬក៏គម្របដបទឹក, ផ្លែឈើដែលមានរាងមូល), ដបទឹក



១. ចែកកុមារជាក្រុម ដែលមួយក្រុមមានគ្នា ៤នាក់
២. ដាក់កៅអីមួយដែលមានកូនបាល់៤ និងដបទឹក៤ (ប្រើដបទឹកប្លាស្ទិក និងដាក់ទឹកក្នុងនោះ ដើម្បីកុំឲ្យដបដួល) សម្រាប់កុមារ ៤នាក់។
៣. ឲ្យក្រុមទី១ ប្រគៀកដៃគ្នា ហើយដើរទៅកាន់តុដែលមានកូនបាល់រួចយកកូនបាល់ម្នាក់មួយ។



៤. បន្ទាប់មកពួកគេត្រូវយកកូនបាល់នោះទៅដាក់ពីលើដបទឹកមិនឲ្យដួលឬក៏ធ្លាក់នោះទេ។
៥. ក្រុមណាដែលអាចដាក់កូនបាល់នៅលើដបបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក្រុមដែលឈ្នះបានធ្វើជាមួយគ្នា ដើម្បីសម្រេចនូវគោលដៅរបស់ពួកគេ។ ក៏ដូចគ្នានេះដែរ អ្នកប្រាជ្ញទាំង៣ នៅក្នុងព្រះគម្ពីរនៅថ្ងៃនេះ បានធ្វើការជាមួយគ្នា ដើម្បីស្វែងរកព្រះយេស៊ូវ ពីព្រោះគ្រប់គ្នាត្រូវការព្រះយេស៊ូវ។

### ៤. ការណែនាំមេរៀន

មនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែដឹងនោះទេ។ ព្រះគម្ពីរប្រាប់យើងថា មនុស្សទាំងអស់បានប្រព្រឹត្តអំពើបាប ហើយខ្វះសិរីរុងរឿងរបស់ព្រះ។ ដោយសារយើងទាំងអស់គ្នា មានអំពើបាប យើងទាំងអស់គ្នាត្រូវការព្រះយេស៊ូដើម្បីសង្គ្រោះយើង។ មនុស្សគ្រប់គ្នាត្រូវការព្រះយេស៊ូវ! ព្រះយេស៊ូវបានយាងមកសម្រាប់មនុស្សគ្រប់គ្នា។ ថ្ងៃនេះយើងនឹងរៀនអំពីរបៀបដែលព្រះបានដឹកនាំអ្នកប្រាជ្ញមួយចំនួន

ធ្វើដំណើរមកពីកន្លែងឆ្ងាយមកក្រុងបេថ្លេហិម ដើម្បីស្វាគមន៍ព្រះយេស៊ូវជាស្ដេច។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះយេស៊ូវប្រសូតនៅភូមិបេថ្លេហិម មានអ្នកប្រាជ្ញបីនាក់មកពីទិសខាងកើតមកក្រុងយេរូសាឡិម ។ ពួកគេចូលទៅគាល់ស្ដេចហេរ៉ូឌនៃជនជាតិអ៊ីស្រាអែល ហើយសួរទ្រង់ថាតើស្ដេចដែលទើបកើតនោះនៅទីណា។ ស្ដេចហេរ៉ូឌមិនសប្បាយចិត្តពេលបានឮដូច្នេះ ពីព្រោះទ្រង់ជាស្ដេច។ ទ្រង់មិនចង់មានស្ដេចផ្សេងទៀតទេ។ ប៉ុន្តែអ្នកប្រាជ្ញសាសន៍ដទៃមកពីទីឆ្ងាយពន្យល់ថា ពួកគេបានមើលឃើញផ្កាយ ហើយពួកគេដើរតាមផ្កាយមួយនោះដែលជាសញ្ញានៃស្ដេចទើបនឹងប្រសូត។

ដូច្នេះ ស្ដេចហេរ៉ូឌបានហៅពួកហោរ៉ារបស់ទ្រង់ ហើយសួរពួកគេថា តើព្រះមេស្ស៊ីនឹងប្រសូតនៅទីណា។ ពួកគេបានឆ្លើយថា "នៅបេថ្លេហិម" ។ ដូច្នេះ ស្ដេចហេរ៉ូឌបានប្រាប់ពួកអ្នកប្រាជ្ញឱ្យទៅភូមិបេថ្លេហិម ដើម្បីស្វែងរកស្ដេចនេះ ហើយប្រាប់ឱ្យគាត់ដឹង ដើម្បីគាត់បានទៅថ្វាយបង្គំស្ដេចថ្មី។ ប៉ុន្តែស្ដេចហេរ៉ូឌចង់សម្លាប់ស្ដេចថ្មីដែលកើតក្នុងស្រុកអ៊ីស្រាអែលនោះ។

ពួកគេបានបន្តដើរតាមផ្កាយ ហើយអាចរកឃើញទារកយេស៊ូវដែលបាននៅជាមួយនឹងម្ដាយរបស់ទ្រង់។ ពួកគេ រីករាយជាខ្លាំងដែលបានជួបព្រះមេស្ស៊ី ហើយបានថ្វាយបង្គំទ្រង់។ ទោះបីជាពួកគេជាសាសន៍ដទៃក៏ដោយពួកគេបានដឹងថាពួកគេត្រូវការព្រះអង្គសង្គ្រោះ ហើយពួកគេរីករាយដែលបានរកឃើញទ្រង់នៅបេថ្លេហិម។ នេះជារឿងសំខាន់ណាស់ ព្រោះវាបង្ហាញយើងថាព្រះយេស៊ូវមិនគ្រាន់តែមកសម្រាប់អ៊ីស្រា-អែលប៉ុណ្ណោះទេ។ ព្រះយេស៊ូវបានយាងមកសម្រាប់មនុស្សគ្រប់គ្នាដែលរួមមានមនុស្សមកពី អាមេរិក អឺរ៉ុប អាហ្វ្រិក ចិន អូស្ត្រាលី និងសូម្បីតែប្រទេសកម្ពុជា!

យើងទាំងអស់គ្នាត្រូវការក្ដីស្រឡាញ់។ យើងទាំងអស់គ្នាត្រូវការការអត់ទោស។ យើងទាំងអស់គ្នាត្រូវការព្រះអង្គសង្គ្រោះ។ យើងទាំងអស់គ្នាត្រូវការព្រះយេស៊ូវ។ មនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ។ ហើយពេលដែលយើងទុកចិត្តលើព្រះយេស៊ូវ ហើយប្រាប់ទ្រង់ថា យើងត្រូវការទ្រង់ នោះទ្រង់នឹងសង្គ្រោះយើង។ យើងក៏ត្រូវតែចែករំលែកដំណឹងល្អនេះជាមួយមិត្តភ័ក្ដិ និងក្រុមគ្រួសាររបស់យើងដែរ ដើម្បីឲ្យអ្នករាល់គ្នាដែលយើងស្គាល់បានស្គាល់ព្រះយេស៊ូវដែរ។ ចូរចាំថា មនុស្សគ្រប់រូបត្រូវការព្រះយេស៊ូវ ហើយព្រះយេស៊ូវបានយាងមកសម្រាប់អ្នករាល់គ្នា!

## ៦. សំនួរពិភាក្សា

១. តើនរណាធ្វើដំណើរមកក្រុងយេរូសាឡិមដើម្បីស្វែងរកព្រះយេស៊ូវ?
*(អ្នកប្រាជ្ញទាំងបីមកពីទិសខាងកើត)*
២. តើនៅទីក្រុងណាដែលពួកគេបានរកឃើញព្រះយេស៊ូវដូចបានទាយក្នុងគម្ពីរ? *(បេថ្លេហិម)*
៣. ហេតុអ្វីរឿងនេះសំខាន់? *(ព្រោះវាបង្ហាញថាព្រះយេស៊ូវមិនគ្រាន់តែប្រសូត្រ មកសម្រាប់អ៊ីស្រាអែលប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់មនុស្សគ្រប់គ្នាក្នុងពិភពលោកនេះ)*
៤. តើអ្នកអាចចែកចាយដំណឹងល្អនេះដល់អ្នកឯទៀតយ៉ាងដូចម្ដេច? *(ទុកឱ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ចាប់ផ្កាយ»

សម្ភារៈដែលត្រូវការៈ កែវជ័រ កូនបាល់(ឬក៏គម្របដប ឬស្ករគ្រាប់)



១. ចែកកុមារជា ២ ឬ៣ ក្រុមហើយឲ្យពួកគេឈរជាជួរ
២. ក្រុមទាំង២ ត្រូវឈរជាជួរចម្ងាយ ២ម៉ែត្រពីគ្នា។
៣. ឲ្យកូនបាល់ ៥ ទៅក្រុមនីមួយៗ។



៤. កុមារទីមួយ នឹងដាក់កូនបាល់ទៅក្នុងកែវដ័រួចបោះវាឲ្យទៅកុមារបន្ទាប់។ កុមារបន្ទាប់ត្រូវចាប់បាល់នោះ ហើយបោះទៅឲ្យកុមារបន្តបន្ទាប់រហូតដល់កុមារចុងក្រោយ។

៥. ក្រុមណាដែលអាចបោះបាល់ទាំងអស់ទៅដល់កុមារចុងក្រោយបានមុនគេក្រុមនោះនឹងឈ្នះល្បែងនេះ

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កូនបាល់ប្រៀបបាននឹងផ្កាយអីចឹង។ បើទោះបីជាយើងពិបាកក្នុងតាមចាប់ផ្កាយក៏ដោយ យើងមិនគួរបោះបង់ការតាមស្វែងរកព្រះយេស៊ូវដូច្នេះដែរ ពីព្រោះយើងគ្រប់គ្នាត្រូវការព្រះយេស៊ូវ។

## ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ១០៖១៣** *"ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះ អម្ចាស់ នោះនឹងបានសង្គ្រោះ។"*

**៩. ហាត្ថកម្ម៖** ជាត់ពណ៌រូបភាព "អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ" និងសរសេរព្រះគម្ពីរចងចាំ

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
មិនថាយើងនៅក្នុងដំណាក់កាលណាក្នុងជីវិត យើងអាចថ្វាយបង្គំព្រះយេស៊ូវបាន។ សូមអានដំណើររឿងនៃការថ្វាយបង្គំរបស់ម៉ាហ្គីនៅក្នុង ម៉ាថាយ ២៖១-១២។ សូមពិចារណាអំពីចំណុចនេះ៖ តើអ្នកគិតយ៉ាងណាចំពោះរបៀបដែលអ្នកថ្វាយបង្គំព្រះយេស៊ូវ? យើងអាចថ្វាយបង្គំនៅកន្លែងណាក៏បាន គ្រប់ពេលដែលយើងចង់ថ្វាយបង្គំ។ ប៉ុន្តែយើងមានទំនួលខុសត្រូវដ៏ធំមួយដែលគ្មានអ្នកណាបង្ខំយើង ឲ្យ (ឬមិន) ថ្វាយបង្គំឡើយ។ យើងគួរតែគោរពប្រណិប័តន៍ព្រះយេស៊ូវដោយសេចក្តីស្រឡាញ់និងការលះបង់របស់យើងចំពោះទ្រង់។ អរគុណព្រះយេស៊ូវសម្រាប់ព្រះគុណរបស់ទ្រង់ សម្រាប់ការទទួលយកការថ្វាយបង្គំរបស់យើង ទោះជាយើងមានបាបច្រើនក៏ដោយ។

# អ្នកប្រាជ្ញថ្វាយបង្គំព្រះយេស៊ូវ



សូមសរសេរខគម្ពីរចងចាំ: ____________________________

________________________________________________

________________________________________________

________________________________________________

________________________________________________